# ដោះម៉ែ

(ពៅសុខ)

ពាក្យ៧ គោព័ទ្ធស្ទឹង

-កូនមានជីវិតត្បិតទឹកដោះ ដោះម៉ែឥតខ្ទោះចិញ្ចឹមកូន

កូនមិនតែមួយមានបងប្អូន ប្អូនបងប្រែសូន្យភ្លេចគុណម៉ែ

-ម៉ែអើយដោះម៉ែប្រែអភ័ព្វ ភ័ព្វព្រេងមិនគាប់ជាប់មិនល្ហែ

ល្ហែល្ហើយមិនស្បើយព្រោះរោគស្នេហ៍ ស្នេហ៍យកដោះម៉ែលម្អកាយ។

-កាយម៉ែកុំខឹងនឹងគេថ្មី ថ្មីសហស្សវត្សរ៍ថ្មីចិត្តគេណាយ

ណាយគុណដោះម៉ែឥតខ្វល់ខ្វាយ ខ្វាយខ្វល់ដោះម្ដាយធ្លាប់ថ្លៃថ្នូរ

-ថ្នូរជាមាសប្រាក់ធាក់ឱ្យល្វិត ល្វិតល្ងង់ជីវិតឈ្មោះជាស្នូរ

ស្នូរស្ពានប្រាណស្នគ្រលះផ្ដាច់ប្ដូរ ប្ដូរផ្លាស់ហែរហូតាមចិត្តចង់។

-ចង់ល្បែងលែងខ្លួនតាមភ្លើងកាម កាមគុណជក់ដាមរៀចលែងត្រង់

ត្រង់តាមគន្លងដ៏ផ្លូវផង់ ផង់ផេះកន្លង់ប៉ងលេងដោះ។

-ដោះម៉ែតូចក្បំប្រឹងឱ្យធំ ធំពើងដូចត្នំផ្តើនសម្រស់
ស្រស់គេច្របាច់ស្រៀវស្រើបអស់ អស់ស្រួលឥតខ្មោះដោះកេរ្តិ៍ម៉ែ

-ម៉ែខំថៃដោះចិញ្ចឹមកូន កូនវិញយកដោះកំដរស្នេហ៍
ស្នេហ៍ព្រោះដោះធំរំភើបប្រែ ប្រែប្រួលដោះម៉ែអស់តម្លៃ

-ថ្លៃយកដោះម៉ែធ្វើជាល្បែង ល្បែងកាមខ្លួនឯងឥតសំចៃ
ចៃស្នេហ៍រោគជ្រើមទាំងយប់ថ្ងៃ ថ្ងៃយប់ប្រឹងថ្នៃឥតខ្វល់គិត។

-គិតពាក់អាវវាលចេញដោះម៉ែ ម៉ែប្រឹងថ្នមថៃបិទជុំជិត
ជិតមិនឱ្យឃើញទោះញាតិមិត្ត មិត្តរួមជីវិតក៏ម៉ែលាក់។

-លាក់តាំងពីតូចរហូតធំ ធំបាំងស្បៃរុំកន្សែងជាក់
ជាក់ខ្លាចគេឃើញរាងដោះអ្នក អ្នកម្តាយអើយអ្នកកុំខឹងថ្វី។

-ថ្វីស្រុកឥឡូវត្រូវអួតដោះ ដោះឱ្យកំលោះពោះម៉ាយក្តី
ក្តីក្តៅច្របាច់ស្ទាបលិឍឆី ឆីសាច់សខ្ចីនៃតួដោះ។

-ដោះម៉ែសព្វថ្ងៃគេលៃតែ តែដើម្បីស្នេហ៍ជ្រាវញ៉េះ

ញ៉ោះញ៉ោះញាក់ញិញញីញោត់កៀនដោះ ដោះម៉ែប្រែក្រោះខ្សោះខ្លឹមសារ

*ថ្ងៃទី២៣ វិច្ឆិកា ២០០៦*